មាត្រា ១០.-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០

ព្រះហស្ថលេខា

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ នរោត្តម សីហនុ

សូមឡាយព្រះហស្ថលេខា បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

នាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា និងត្រា ហត្ថលេខា និងត្រា

ហ៊ុន សែន គាត ឈន់

★★★

## ២- ព្រះរាជក្រឹត្យ

**ព្រះរាជក្រឹត្យ នស/រកត/០៧០០/១៣៥**

**ស្តីពីលក្ខន្តិកៈដោយឡែក**

**នៃក្របខ័ណ្ឌគ្រូពេទ្យ** 

**នៃក្របខ័ណ្ឌឆ្មាក់ខាររដ្ឋបាល**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

Downloaded from http://www.khmerlaws.com

- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពី គោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទទួលការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៣ ខែមិថុនា ឆ្នាំ ២០០០

## ត្រាស់បង្គាប់

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ដែលត្រូវបានចាត់ថ្នាក់ក្នុងប្រភេទ ឃ ដូចបានចែងក្នុងមាត្រា ៦ នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ។

**មាត្រា ២.-**

ក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ដែលជាកម្មវត្ថុនៃលក្ខន្តិកៈដោយឡែកសំរាប់ក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលនេះ ស្ថិតនៅក្រោមឱវាទរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដែលប្រមូលផ្តុំមន្ត្រីរាជការធ្វើការងាររដ្ឋបាល សំរាប់បណ្តាក្រសួង-ស្ថាប័ននានា ។ ឯការវិវត្តន៍របស់ភ្នាក់ងារម្នាក់ៗ គឺស្ថិតនៅក្រោមក្រសួង-ស្ថាប័នសាមី ។

មិនត្រូវបានអនុញ្ញាតឲ្យបង្កើតក្របខ័ណ្ឌ សំរាប់ធ្វើការងារភ្នាក់ងាររដ្ឋបាលផ្សេងពីក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលឡើយ លើកលែងតែក្រសួងមហាផ្ទៃ ។

**មាត្រា ៣.-**

មន្ត្រីនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល មានឧបនិស្ស័យសំរាប់បំពេញមុខតំណែងក្នុងកិច្ចការប្រតិបត្តិនៅក្នុងអង្គភាពរដ្ឋបាលកណ្តាលខេត្ត-ក្រុង ហើយនឹងក្នុងគ្រឹះស្ថានសាធារណៈរដ្ឋបាលផងដែរ ។

### ជំពូកទី ២

### ឋានន្តរស័ក្តិនៃក្របខ័ណ្ឌ

**មាត្រា ៤.-**

ក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល មាន ៣ ឋានន្តរសក្តិ :

| | |
|---|---|
| -នាយភ្នាក់ងាររដ្ឋបាល | មាន ០៦ ថ្នាក់ |
| -ភ្នាក់ងាររដ្ឋបាលដើមខ្សែ | មាន ១០ ថ្នាក់ |
| -ភ្នាក់ងាររដ្ឋបាល | មាន ១៤ ថ្នាក់ ។ |

Downloaded from http://www.khmerlaws.com

## ជំពូកទី ៣
## ការជ្រើសរើស

**មាត្រា ៥.-**

ការជ្រើសរើសចូលក្នុងក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ត្រូវធ្វើឡើងតាមរយៈការប្រឡងប្រជែង ដែលរៀបចំឡើងដោយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។ ចំនួនតំណែងក្នុងការជ្រើសរើស ត្រូវកំណត់ឡើងដោយរាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

**មាត្រា ៦.-**

ការប្រឡងប្រជែងជ្រើសរើសត្រូវបើកចំហចំពោះបេក្ខជនដែលមានអាយុយ៉ាងច្រើន ២៥ឆ្នាំ គិតមកដល់ថ្ងៃប្រឡង ។ អាយុនេះអាចរំកិលពី ២៥ ឆ្នាំឡើងដល់ ៣០ ឆ្នាំ ស្របតាមមាត្រា ១១ នៃសហលក្ខន្តិក ៈមន្ត្រីរាជការស៊ីវិល ។

## ជំពូកទី ៤
## កម្មសិក្សាសាកល្បង និង ការតាំងស៊ប់

**មាត្រា ៧.-**

បេក្ខជនដែលត្រូវបានជ្រើសរើស ចាំបាច់ត្រូវឆ្លងកាត់រយៈពេលធ្វើកម្មសិក្សាមួយ ដែលប្រព្រឹត្តទៅស្របតាមបទប្បញ្ញត្តិ មាត្រា ១៦ និងមាត្រាបន្តបន្ទាប់ នៃសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

ក្រោយពេលធ្វើកម្មសិក្សាសាកល្បង មន្ត្រីនេះត្រូវបានតាំងស៊ប់ក្នុង ឋានន្តរស័ក្តិ ភ្នាក់ងារ ឬ ក្នុងករណីចាំបាច់អាចត្រូវបានអនុញ្ញាតឱ្យធ្វើកម្មសិក្សាបន្តបន្ថែម ដែលមានរយៈពេលអតិបរមាត្រឹម ១២ ខែ ។ មន្ត្រីដែលពុំបានទទួលជោគជ័យក្នុងការធ្វើកម្មសិក្សាបន្ថែមនេះត្រូវបានលុបឈ្មោះចោល ។ ករណីខាងលើទាំងនេះ ត្រូវសំរេចដោយប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ តាមសំណើរបស់ក្រសួង-ស្ថាប័នសាមីដោយបញ្ជាក់នូវមូលហេតុ ហើយត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរ ៣ ខែ ក្រោយការបញ្ចប់កម្មសិក្សា ។ ការតែងតាំងជាភ្នាក់ងាររដ្ឋបាលកម្មសិក្សា និងការតាំងស៊ប់ក្នុងឋានន្តរស័ក្តិភ្នាក់ងាររដ្ឋបាលនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

## ជំពូកទី ៥
## ការតែងតាំង

**មាត្រា ៨.-**

ក្រោយពេលត្រូវបានតាំងស៊ប់ក្នុងឋានន្តរស័ក្តិមួយរួចមក ភ្នាក់ងាររដ្ឋបាលទាំងនេះ ត្រូវបានតែងតាំងក្នុងមុខតំណែងទំនេរមួយ ដែលស្របជាមួយឋានន្តរស័ក្តិរបស់ខ្លួនដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួង-ស្ថាប័នសាមីតាមបែបបទដូចបានកំណត់ក្នុងមាត្រា ២៨ នៃព្រះរាជក្រមចុះ

Downloaded from http://www.khmerlaws.com

ថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។

## ជំពូកទី ៦

## ការតម្លើងថ្នាក់ និង ការតម្លើងឋានន្តរស័ក្តិ

**មាត្រា ៩.-**

មន្ត្រីនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ត្រូវបានតម្លើងថ្នាក់ទៅតាមលក្ខខ័ណ្ឌដូចបានចែងក្នុងមាត្រា ២០ និងមាត្រាបន្តបន្ទាប់នៃសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

លក្ខណៈសម្បត្តិជាមូលដ្ឋានដែលត្រូវពិនិត្យតម្លើងថ្នាក់មានដូចខាងក្រោម :

-គោរពវិន័យការងារបានត្រឹមត្រូវ

-សម្រេចបានល្អនូវភារកិច្ចដែលប្រគល់ឲ្យ

-មានសីលធម៌ល្អ ។

ការឡើងថ្នាក់ នៃអ្នករាជការក្នុងក្របខ័ណ្ឌនេះ ត្រូវគិតក្នុងសមាមាត្រ ៣ ភាគ ៤ តាមវេនជ្រើសរើស និង ១ ភាគ ៤ ក្នុងវេនអតីតភាព ។

**មាត្រា ១០.-**

គោលការណ៍នៃការតម្លើងឋានន្តរស័ក្តិ ត្រូវតម្លើងទៅក្នុងថ្នាក់ដំបូងនៃឋានន្តរស័ក្តិខ្ពស់លើបន្ទាប់ ឬ ក្នុងករណីចាំបាច់ ត្រូវតម្លើងទៅក្នុងថ្នាក់ ដែលស្របជាមួយសន្ទស្សន៍ខ្ពស់លើ បន្ទាប់ពីសន្ទស្សន៍ចាស់របស់មន្ត្រីសាមី ។

ការតម្លើងឋានន្តរស័ក្តិ ត្រូវអនុវត្តឲ្យបានស្របជាមួយចំនួនតំណែងដែលមានទំនេរ នៅក្នុងឋានន្តរស័ក្តិនោះ ហើយត្រូវធ្វើតាមរយៈការចុះឈ្មោះក្នុងតារាងតម្លើងឋានន្តរស័ក្តិ ឬតាមរយៈការប្រឡងប្រជែង ដោយរក្សាគោលការណ៍គិតជាភាគរយ :

-ឋានន្តរស័ក្តិនាយភ្នាក់ងាររដ្ឋបាល = ៥ ភាគរយ

-ឋានន្តរស័ក្តិភ្នាក់ងាររដ្ឋបាលដើមខ្សែ = ២៥ ភាគរយ

-ឋានន្តរស័ក្តិភ្នាក់ងាររដ្ឋបាល = ៧០ ភាគរយ

ការតម្លើងថ្នាក់ និងតម្លើងឋានន្តរស័ក្តិ ត្រូវសំរេចតាមប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

**មាត្រា ១១.-**

អាចតម្លើងទៅក្នុងឋានន្តរស័ក្តិភ្នាក់ងាររដ្ឋបាលដើមខ្សែ គឺមន្ត្រីទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ១១ នៃឋានន្តរស័ក្តិភ្នាក់ងាររដ្ឋបាល ។ អាចតម្លើងទៅក្នុងឋានន្តរស័ក្តិនាយភ្នាក់ងាររដ្ឋបាល គឺមន្ត្រីទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ ៧ នៃឋានន្តរស័ក្តិភ្នាក់ងាររដ្ឋបាលដើមខ្សែ ។

Downloaded from http://www.khmerlaws.com

មាត្រា ១២.-

សន្ទស្សន៍សំរាប់ថ្នាក់ក្នុងឋានន្តរស័ក្តិនីមួយៗនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល និងតំលៃឯកតានៃសន្ទស្សន៍ព្រមទាំងរបបពាក់ការផ្សេងៗទៀត ត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក ។

## ជំពូកទី ៧
## បទប្បញ្ញត្តិដោយឡែក

មាត្រា ១៣.-

មន្ត្រីនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ត្រូវដាក់ឲ្យចូលនិវត្តន៍ពេលដល់អាយុ ៥៥ឆ្នាំ ។

ចំពោះការដាក់ឲ្យចូលនិវត្តន៍ សំរេចដោយប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

## ជំពូកទី ៨
## អន្តរប្បញ្ញត្តិ

មាត្រា ១៤.-

ចំនួនដំបូងនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ត្រូវកសាងចេញពីសមាហរណកម្មមន្ត្រីទាំងឡាយដែលបច្ចុប្បន្នកំពុងបំពេញមុខងារពិតប្រាកដរបស់ក្របខ័ណ្ឌនៅរដ្ឋបាលកណ្តាល និងខេត្ត-ក្រុង ។

## ជំពូកទី ៩
## អវសានប្បញ្ញត្តិ

មាត្រា ១៥.-

រាល់បទប្បញ្ញត្តិណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៦.-

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ហ៊ុន សែន

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី
សូមចុះហត្ថលេខា
ហត្ថលេខា និងត្រា
ពេជ្រ ម៉ុនធិន

★★★

Downloaded from http://www.khmerlaws.com